# ជំពូកទី ១០

## ១០. សន្និដ្ឋាន និង អនុសាសន៍

### ១០.១ សន្និដ្ឋាន

ទោះបីជាសំណើរោងចក្រវារីអគ្គិសនីសេសាន២ នឹងផលិតនូវថាមពលយ៉ាងធំ (1953.9 GWh ក្នុងមួយឆ្នាំ) សំរាប់ប្រទេសកម្ពុជា និង នាំចេញទៅប្រទេសជុំវិញ ហើយនឹងជួយអភិវឌ្ឍន៍ប្រទេសជាតិក៏ដោយ ក៏គំរោងនេះនឹងបង្កនូវផលប៉ះពាល់គួរអោយកត់សំគាល់មួយចំនួនដល់ធនធានបរិស្ថាន និងសង្គម ដែលត្រូវតែធ្វើការថ្លឹងថ្លែងលើផលចំណេញសេដ្ឋកិច្ចរបស់គំរោង នៅពេលដែលគេធ្វើសេចក្តីសំរេចចិត្តថា តើគំរោងនេះត្រូវធ្វើទៅបានឬក៏អត់។ យ៉ាងណាមិញស្ថានភាពដីនៃតំបន់ទំនប់ដែលបានស្នើសុំជាវាលរាប នោះនឹងមានការលិចលង់លើផ្ទៃដីចំនួន ៣០.៥៧៤ ហិកតា ដោយរាប់បញ្ចូលទាំងព្រៃឈើ ដែលជាជំរកដល់ពូជសត្វកំរ និង កំពុងរងគ្រោះជាច្រើនប្រភេទ ព្រមទាំងដីកសិកម្ម និងដីភូមិ លំនៅដ្ឋានរបស់ប្រជាជនដែលមិនមានបំណងនឹងធ្វើការផ្លាស់ទីកន្លែង ប្រហែល ៥.០០០នាក់ ។ ទំនប់នេះនឹងជារនាំងឧបសគ្គដល់បំលាស់ទីឡើងចុះរបស់ត្រី ដែលនាពេលបច្ចុប្បន្នផ្តល់នូវការផ្គត់ផ្គង់ត្រីដែលជាប្រភពអាហារយ៉ាងសំខាន់មួយផ្នែកធំ សំរាប់ប្រជាជនដែលរស់នៅតាមដងទន្លេប្រហែលជា ៥០.០០០នាក់ ដូច្នេះជាចាំបាច់ទាមទារនូវការថ្លឹងថ្លែងពីសេដ្ឋកិច្ចអោយបានត្រឹមត្រូវ ដើម្បីអោយគំរោងអាចសាងសង់ទៅបាន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ វាមិនមែនជាបំណងរបស់ EIA ដើម្បីធ្វើការសំរេចចិត្តថាតើគំរោងគួរធ្វើ ឬ មិនធ្វើនោះទេ គឺវាអាស្រ័យទៅតាមបច្ច័យជាច្រើនទៀត ដែលជាប់ទាក់ទងដល់ការសំរេចយកសំរាប់អ្នកដែលមានសិទ្ធិសំរេចធ្វើការអនុម័ត។ ការសិក្សា EIA ត្រូវបានបង្ហាញនូវអ្វីដែលជាហេតុប៉ះពាល់របស់ការអភិវឌ្ឍន៍នេះ ដែលនឹងកើតមានឡើងដោយសារសកម្មភាពគំរោង និងបង្ហាញនូវវិធានការបន្ធូរបន្ថយនឹងត្រូវអនុវត្ត ដើម្បីកាត់បន្ថយហេតុប៉ះពាល់សំខាន់ៗដល់កំរិតអប្បបរិមា ដែលគេគួរសំរេចថាគំរោងនោះអាចធ្វើទៅបាន ។ ភាពមិនគោរពតាមនៃវិធានការបន្ធូរបន្ថយដែលបានលើកឡើងទំនងនឹងបណ្តាលអោយមានហេតុប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និង សង្គម ដែលជាលទ្ធផលចេញពីទំនប់រយៈពេលជាច្រើនឆ្នាំ ហើយនឹងប៉ះពាល់ដល់មនុស្សម្នាជំនាន់ក្រោយរបស់កម្ពុជា។ វានឹងក្លាយជាទំនួលខុសត្រូវរបស់អ្នកធ្វើសេចក្តីសំរេចចិត្តទាំងឡាយ ក្រុមហ៊ុនសាងសង់ទំនប់ និងស្ថាប័នផ្សេងទៀត ដើម្បីធានាបានថា វិធានការបន្ធូរបន្ថយត្រូវបានអនុវត្តតាមយ៉ាងត្រឹមត្រូវ ដើម្បីធានាបានថាហេតុប៉ះពាល់សំខាន់ៗ ត្រូវបានកាត់បន្ថយអោយបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

Draft

នាពេលបច្ចុប្បន្ននេះ គំរោងស្ថិតនៅក្នុងដំណាក់កាលសិក្សាពីសមិទ្ធិលទ្ធភាព ហើយដំណាក់កាលរៀបចំប្លង់លំអិត ដំណាក់កាលប្រតិបត្តិការ នឹងត្រូវធ្វើនៅឆ្នាំខាងមុខនេះ (២០០៩-២០១៤)។ តំលៃវិនិយោគសរុបសំរាប់គំរោងនេះមានចំនួនប្រមាណជា **៨១៦.២៣លានដុល្លាអាមេរិក** ហើយគំរោងនេះជាគំរោងប្រភេទ **BOT (សាងសង់ ប្រតិបត្តិការ និងផ្ទេរ)** ដែលមានរយៈពេលប្រតិបត្តិការ ៣០ឆ្នាំ។

ធនធានធម្មជាតិនៅក្នុងតំបន់គំរោងនាពេលបច្ចុប្បន្ននេះរួមមាន ព្រៃឈើ និងសត្វព្រៃយ៉ាងសំបូរបែប មានខ្យល់ល្អបរិសុទ្ធ និងទឹកទន្លេមានគុណភាពល្អគួរសម ។ តំបន់ព្រៃមួយចំនួនផ្ទុកនូវគុណតំលៃបរិស្ថានយ៉ាងខ្ពស់សំរាប់ជំរុកសត្វព្រៃ។ វាគឺជាផ្នែកមួយនៃប្រព័ន្ធ-អេកូឡូស៊ីព្រៃស្ងួតរបស់ទន្លេមេគង្គក្រោម ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិថា ជាជំរកផ្ទុកសត្វព្រៃដ៏មានតំលៃ ប្រភេទពូជកំរ និង ពូជកំពុងរងគ្រោះថ្នាក់។ ម្យ៉ាងវិញទៀត ប្រជាជនដែលរស់នៅក្នុងតំបន់គំរោងភាគច្រើនជាក្រុមជនជាតិភាគតិច ដែលចូលចិត្តរស់នៅជាភូមិតាមដងទន្លេសេសាន និងស្រែពកអស់រយៈកាលយូរយារណាស់មកហើយ។ មិនមានឃើញតំបន់បុរាណសាស្ត្រ ឬ វត្ថុបុរាណ មានវត្តមាននៅក្នុងតំបន់នោះទេ ។ ទោះបីយ៉ាងណាក៏ដោយ មានកន្លែងទឹកធ្លាក់ ឬទឹកជ្រូរពីរបីកន្លែងស្ថិតនៅតំបន់ ខ្សែទឹកខាងក្រោមនៃតំបន់គំរោង ដែលមានសក្តានុពលសំរាប់អេកូទេសចរណ៍ផងដែរ ។

ក្នុងកំឡុងពេលសាងសង់ និងប្រតិបត្តិរបស់គំរោង ហេតុប៉ះពាល់ជាអវិជ្ជមានគួរអោយកត់សំគាល់មួយចំនួនទៅលើធនធានធម្មជាតិ និង សង្គមនៅក្នុងតំបន់គំរោងនឹងកើតមានឡើង។ ផ្ទៃដីប្រមាណជា ៣០,៥៧៤ ហ.ត នឹងត្រូវលិចលង់ រាប់បញ្ចូលទាំងព្រៃឈើ ដីកសិកម្ម និង លំនៅដ្ឋាន។ គំរោងនឹងប៉ះពាល់ដល់ ១០៥៩ គ្រួសារ មានប្រជាជន ៤៧៨៥ នាក់ (ប្រជាជននៅក្នុងឆ្នាំ ២០០៧) រឺ ១៥៧៩ គ្រួសារ មានប្រជាជន ៦៥០៧ នាក់ (ព្យាករណ៍ ២០១១) ដែលតំរូវឱ្យធ្វើការតាំងលំនៅសារជាថ្មី។ ហេតុប៉ះពាល់ទៅលើរបបជលសាស្ត្ររបស់ទន្លេសេសាននឹងមានកំរិតតិចតួចដោយសារការរៀបចំប្លង់បញ្ចេញទឹក។ ហេតុប៉ះពាល់ទៅលើវារីសត្វ/ត្រីក្នុងតំបន់មានកំរិតខ្លាំង និង ហេតុប៉ះពាល់ទៅលើសត្វព្រៃមានកំរិតមធ្យម ដោយសារការសាងសង់ទំនប់ និងកិច្ចដំណើរការគំរោង ។ គុណភាពទឹកក្នុងទន្លេសេសាននឹងត្រូវផ្លាស់ប្តូរ ហើយគុណភាពភាពទឹកថយចុះត្រូវបានរំពឹងទុក ជាពិសេសក្នុងពេលសាងសង់ និងអំឡុងពេលពីរបីឆ្នាំនៃកិច្ចប្រតិបត្តិការគំរោងដំបូង។ ធូលី ផ្សែងក្រខ្វក់ សំលេងរំខាន និង រំញ័រចេញ ពីសកម្មភាពសាងសង់ អាចប៉ះពាល់ដល់សត្វព្រៃ និងសុខភាពមនុស្ស ។ ហេតុប៉ះពាល់ទៅលើសុខភាពសាធារណៈ អាចកើតឡើងនៅក្នុងតំបន់សាងសង់ ជំងឺគ្រុនចាញ់ ជំងឺសង្គមដូចជា HIV/AIDS ជំងឺកាមរោគផ្សេងទៀត និង គ្រោះថ្នាក់ចរាចរ ។ល។ ក៏ដូចជាការសេពនិងការធ្វើចរាចរណ៍ថ្នាំញៀន និងគ្រឿងស្រវឹងផ្សេងៗពីសំណាក់កម្មករឬបុគ្គលិកគំរោងនៅក្នុងសហគមន៍មូលដ្ឋាន ។ ទោះបីជាយ៉ាងណាក៏ដោយ វិធានការកាត់បន្ថយបានផ្តល់ជាអនុសាសន៍នៅក្នុង EMP សំរាប់គំរោងអាចកាត់បន្ថយហេតុប៉ះពាល់ទាំងនោះ បានមួយចំនួនធំផងដែរ។

Draft

បណ្តុំប៉ះពាល់នឹងកើតឡើងផងដែរនៅកំឡុងពេលសាងសង់ និងក្នុងដំណាក់កាលប្រតិបត្តិ ពីបន្សំរួមគ្នានៃរោងចក្រវារីអគ្គិសនីនៅក្នុងតំបន់រងទឹកភ្លៀងទន្លេសេសាន និង ទន្លេស្រែពក ។ បណ្តុំហេតុប៉ះពាល់រួមមាន ហេតុប៉ះពាល់លើអាកាសធាតុ របបជលសាស្ត្រ ព្រៃឈើ ត្រី និង ជំរកសត្វព្រៃ និងសត្វព្រៃ។ ជាអនុសាសន៍ដ៏ចាំបាច់មួយគឺគ្រប់ក្រុមហ៊ុនថាមពលទាំងអស់ ដែលមានទំនប់វារីអគ្គិសនីនៅក្នុងផ្ទៃរងទឹកភ្លៀងនេះ ត្រូវធ្វើការសំរបសំរួល និងសហការគ្នាក្នុងការគ្រប់គ្រង និង កាត់បន្ថយបណ្តុំហេតុប៉ះពាល់អោយបានច្រើនតាមដែលអាចធ្វើបាន។

ទន្ទឹមនេះគំរោងនឹងផ្តល់ផលប៉ះពាល់ជាវិជ្ជមានដល់ប្រទេសកម្ពុជា ដូចជាការផ្តល់ថាមពលដល់កម្ពុជា និង ប្រទេសជិតខាង និងផ្តល់ជាការងារជាច្រើនដល់កម្មករ និងប្រជាជនក្នុងមូលដ្ឋានរហូតដល់រាប់ពាន់នាក់ក្នុងនៅដំណាក់កាលសាងសង់ បង្កើនប្រាក់ចំណូលដល់ប្រជាជនមូលដ្ឋានមួយចំនួន ។ ហើយគំរោងនិងធ្វើអោយប្រសើរឡើងនូវសកម្មភាពអភិវឌ្ឍន៏ផ្សេងទៀត ដើម្បីទ្រទ្រង់កំនើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា ។

ហេតុដូចនេះគេអាចសន្និដ្ឋានបានថា នឹងមានហេតុប៉ះពាល់ជាអវិជ្ជមានគួរអោយកត់សំគាល់ទៅលើធនធានបរិស្ថាននិងសង្គម ប៉ុន្តែតាមរយៈការអនុវត្តន៏វិធានការកាត់បន្ថយដែលបានផ្តល់ជាអនុសាសន៏នៅក្នុង EMP នោះហេតុប៉ះពាល់ជាអវិជ្ជមាននឹងបានទូទាត់និងបន្ថយមួយចំនួនធំ ។ គំរោងនឹងនាំមកនូវផលចំណេញផងដែរដល់សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និង សេដ្ឋកិច្ចតំបន់ ។

## ១០.២ អនុសាសន៍

តាមការប្រម៉ើលមើលដែលថា គំរោងអាចមានហេតុប៉ះពាល់គួរអោយកត់សំគាល់ ទៅលើធនធានបរិស្ថាន និង ធនធានសង្គមក្នុងតំបន់ នោះអនុសាសន៏មួយចំនួនបានរៀបចំឡើងដូចខាងក្រោម:

- ទំហំអាងស្តុកទឹកត្រូវកាត់បន្ថយអោយបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយនៃផ្ទៃដីដែលនឹងត្រូវលិចលង់ និង បន្ថយគ្រប់ផលវិបាកដែលចេញពីហេតុប៉ះពាល់ទាំងអស់នេះ ។
- ត្រូវផ្តល់អោយបានសមរម្យនូវសំណង និងការតាំងលំនៅសារជាថ្មី ទៅដល់ប្រជាជនដែលនឹងត្រូវរងផលប៉ះពាល់ដោយផ្ទាល់ និង ដោយប្រយោលដោយសារគំរោង ជាពិសេសសំរាប់ភូមិដែលលិចលង់ក្នុងតំបន់អាងស្តុកទឹក និង សំរាប់ភូមិនៅតាមដងទន្លេ ដែលទទួលរងផលលំបាកពីស្តុកត្រីធម្មជាតិដែលថយចុះ ។
- បង្កើតស្ថានីយ៏ភ្ញាស់កូនត្រី និងធ្វើការស្រាវជ្រាវពីវារីសត្វ និង វារីរុក្ខជាតិ និងវិធីសាស្ត្រ ដើម្បីជំនួសការបាត់បង់ត្រីដែលធ្វើបំលាស់ទីទៅខ្សែទឹកខាងលើនៃទំនប់ ។
- បង្កើតស្ថានីយ៏បណ្តុះកូនឈើ និងការដាំឈើនៅក្នុងតំបន់ក្បែរខាងគំរោង ។
- យ៉ាងហោចណាស់ទឹក ១០០ម$^{៣}$/វិនាទី ត្រូវបញ្ចេញឥតដាច់ពីទំនប់នីមួយៗ ក្នុងករណីដែលផ្អាកដំណើរការ ដើម្បីរក្សាប្រព័ន្ធអេកូឡូស៊ី នៅខ្សែទឹកខាងក្រោមអោយនៅមានជីវិត ហើយធារទឹកចេញពីទំនប់ត្រូវពិនិត្យតាមដានជាប់លាប់ ។
- គុណភាពទឹកនៅក្នុងអាងស្តុក និង នៅខ្សែទឹកខាងក្រោមរបស់រចនាសម្ព័ន្ធគំរោងត្រូវពិនិត្យតាមដានអោយបានទៀងទាត់ ហើយចាត់វិធានការអោយបានទាន់ពេលវេលា នៅពេលដែលគុណភាពទឹក មានការបំពុលដែលបង្កដោយទំនប់វារីអគ្គិសនីនេះ ។
- ដើមឈើមានតំលៃនៅក្នុងតំបន់អាងស្តុកទឹកត្រូវបានកាប់ និង យកទៅប្រើវាសំរាប់គោលបំណងផ្សេងទៀតនៅមុនពេលបំពេញទឹកនៅក្នុងអាង ។

Draft

- មូលនិធិបរិស្ថានសមស្របមួយគួរត្រូវបានរៀបចំ ដើម្បីធ្វើអោយប្រាកដនូវប្រសិទ្ធិភាព ចំពោះការទូទាត់សង និង ការគ្រប់គ្រងបរិស្ថាន ។
- តំបន់ជំរកសត្វព្រៃសំខាន់ៗដែលនៅសេសសល់ ត្រូវការពារអោយបានជិតដល់តាមដែលអាចធ្វើទៅបាន។
- តំរូវអោយមានការបោសសំអាតមីននៅកន្លែងសាងសង់ និង ការការដ្ឋានយកថ្មដី ជាពិសេសតំបន់តាំងទីលំនៅសារជាថ្មីរបស់គំរោង មុនការអនុវត្តន៏គំរោង ។
- គ្រប់វិធានការកាត់បន្ថយ ដែលបានផ្តល់ជាអនុសាសន៏នៅក្នុង EMP ត្រូវអនុវត្តអោយបានពេញលេញ។

ក្រុមហ៊ុន EVNI មានសំណូមពរដល់ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយបង្កលក្ខណះងាយស្រួល និងចេញលិខិតអនុញ្ញាតិអោយក្រុមហ៊ុនយើងខ្ញុំ ស្របទៅតាមច្បាប់វិនិយោគ និង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ បានទាន់ពេលវេលាដែលបានគ្រោងទុកយ៉ាងពិតប្រាកដ ។

ភ្នំពេញ ថ្ងៃទី ....... ខែ ............... ឆ្នាំ ២០០៩

ក្រុមហ៊ុនសិក្សាគំរោង PECC1

**អគ្គនាយក**

**Le Van Luc**

ភ្នំពេញ ថ្ងៃទី ....... ខែ ............... ឆ្នាំ ២០០៩

ក្រុមហ៊ុនរៀបចំរបាយការណ៏ EIA

**អគ្គនាយក**

**សោម មិថុនារ័ត្ន**

ភ្នំពេញ ថ្ងៃទី ....... ខែ ............... ឆ្នាំ ២០០៩

ក្រុមហ៊ុនវិនិយោគ

**ប្រធានការិយាល័យតំណាង** EVNI

**Nguyen Van Tuan**

Draft